# គម្រោងអាជីវកម្មចិញ្ចឹមទាកាប៉ា

# Raising Muscovy Ducks





រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែតុលា ឆ្នាំ២០២៣

**មាតិកា**

**១- សេចក្តីផ្តើម** ....... ១
**២-លក្ខណៈទូទៅ**....... ១
**៣-បច្ចេកទេសចិញ្ចឹម** ....... ១
៣-១-ការរៀបចំទីជម្រក....... ១
៣-២-ការជ្រើសរើសពូជ....... ៣
៣-៣-ការបង្កាត់ពូជ ....... ៣
៣-៤-ការភ្ញាស់ស៊ុតតាមលក្ខណៈធម្មជាតិ ....... ៤
៣-៥-ការថែទាំកូនទា ....... ៤
៣-៦-ទឹក និងចំណីទា....... ៦
**៤-វិធី ការការពារ និងការថែរក្សាសុខភាពទាកាប៉ា**....... ៨
**៥-តម្លៃ និងទីផ្សារ**....... ៩
៥-១-តម្លៃ....... ៩
៥-២-ទីផ្សារ....... ៩
៥-៣-គម្រោងនៃការចំណាយលើការចិញ្ចឹមទាកាប៉ាសាច់ ១,០០០ក្បាល....... ១០
៥-៤-ការប្រមូលផល....... ១០
**៦-ការវិភាគសេដ្ឋកិច្ច**....... ១១
៦-១-ការវិភាគលើតម្លៃលក់ទាកាប៉ាសាច់អាយុ៣ខែ ....... ១២
៦-២-ការវិភាគទៅលើអត្រាបាត់បង់....... ១២
**៧-ហានិភ័យ វិធានការ និងអនុសាសន៍** ....... ១៣
**៨-សេចក្តីសន្និដ្ឋាន**....... ១៤

## ១-សេចក្តីផ្តើម

ទាកាប៉ាជាបក្សីមួយប្រភេទងាយស្រួលចិញ្ចឹម ងាយផ្តល់ចំណី ធន់នឹងជំងឺ ធំធាត់លឿន សាច់មានរសជាតិឆ្ងាញ់ ដោយក្នុងសាច់មានសារធាតុខ្លាញ់តិចបំផុត និងមានតម្រូវការទីផ្សារខ្ពស់។ ទាកាប៉ាជាសត្វចូលចិត្តលេងទឹកសម្អាតខ្លួន រស់នៅក្បែរប្រភពទឹក និងស្វែងរកចំណីទាំងក្នុងទឹក និងលើគោក ធន់ទ្រាំនឹងអាកាសធាតុត្រជាក់។ ដើម្បីចិញ្ចឹមទាកាប៉ាទទួលបានជោគជ័យ និងផ្តល់ទិន្នផលខ្ពស់ ទាមទារឱ្យកសិករចិញ្ចឹមត្រូវគិតគូរពីការធ្វើទ្រុង ការជ្រើសរើសពូជ ការបង្កាត់ពូជ របៀបថែទាំ និងការផ្តល់ចំណីដោយអនុវត្តតាមលំដាប់លំដោយនៃបច្ចេកទេសចិញ្ចឹមដែលជាការចាំបាច់បំផុត។

## ២-លក្ខណៈទូទៅ

ពូជទាកាប៉ាដែលចិញ្ចឹមសម្រាប់ផលិតកម្មសាច់ហៅជាភាសាអង់គ្លេស Barbary Duck ចំណែកឯ Muscovy Duck សំដៅលើទាំងពូជទាកាប៉ាព្រៃ និងទាកាប៉ាស្រុក។ ទាកាប៉ាពេញវ័យនៅអាយុ៥ខែ ទៅ៦ខែ។ ទាកាប៉ាឈ្មោលអាចមានទម្ងន់ជាង៦គ.ក្រ ឯទាញីអាចមានទម្ងន់ជាង៣គក្រ។ ទាកាប៉ាមានច្រើនពណ៌ ដូចជា ពណ៌ខ្មៅ ស ប្រផេះ ត្នោត ឬពណ៌គីរ ហើយទាមួយក្បាលអាចមានច្រើនពណ៌។ ទាកាប៉ាចូលចិត្តរស់នៅក្នុងភាពស្ងៀមស្ងាត់ គ្មានសម្លេងរំខាន នៅតាមមាត់បឹង និងចូលចិត្តលេងទឹក ហើយអាចបង្កាត់ពូជបានចាប់ពីអាយុ៧ខែឡើងទៅ។ ទាឈ្មោលច្រើនធំជាងមេ ទាឈ្មោលមានមាឌធំៗមិនអាចហើរឆ្ងាយបានទេ តែទាមេអាចហើរបានឆ្ងាយជាងទាឈ្មោល។ ទាកាប៉ាមានលក្ខណៈពិសេសខុសពីពូជទាដទៃទៀតដូចជា÷ អាចហើរបានទាញីពងដាក់សម្បុកនៅក្នុងទ្រុង និងមានការចងចាំសម្បុកយ៉ាងច្បាស់។ មេទាកាប៉ាមួយក្បាលអាចមានលទ្ធភាពក្រាបស៊ុតរហូតដល់២០គ្រាប់ និងភ្ញាស់កូនមានរយៈពេល៣៥ថ្ងៃ។ សាច់ទាកាប៉ាមានខ្លាញ់តិចជាងប្រភេទទាផ្សេងៗទៀត ។

## ៣-បច្ចេកទេសចិញ្ចឹម

### ៣-១-ការរៀបចំទីជម្រកទាកាប៉ា

***ក)-មានប្រយោជន៍÷***

-មានសុវត្ថិភាពការពារពីសត្វកាចផ្សេងៗ

-ការពារមិនឱ្យទាកាប៉ាចេញទៅស៊ីបំផ្លាញច្បារដំណាំក្នុងកសិដ្ឋាន

-កាត់បន្ថយការឆ្លងជម្ងឺពីខាងក្រៅ

-ស្រួលក្នុងការគ្រប់គ្រង (ការផ្តល់ចំណី ការផ្តល់វ៉ាក់សាំង...)

-ងាយស្រួលក្នុងការប្រមូលផល

## ខ)-ការសាងសង់ទ្រុង៖

-សង់ទ្រុងពីសម្ភារៈងាយៗស្រួលរក

-ទីតាំងស្រួលថែទាំ ទូលាយ ដីមិនស្អិត មិនដក់ទឹក និងមិនមានទឹកហូរឆ្លងកាត់

-មានប្រភពទឹកស្អាត និងមានចំណីធម្មជាតិនៅក្បែរ ដូចជាស្មៅ ត្រកួន និងរុក្ខជាតិផ្សេងៗ

-មានម្លប់ជ្រក និងការពារពីខ្យល់បក់ខ្លាំង

-សង់ទ្រុងមានទទឹង ១០ម៉ែត្រ បណ្ដោយ ៣០ម៉ែត្រឡើងទៅ និងមានដំបូលកម្ពស់ពីដី ៣ម៉ែត្រ (ករណីចិញ្ចឹមទាកាប៉ាពី១,០០០ក្បាល ទៅ១,៥០០ក្បាល) ។ ជាទូទៅទាកាប៉ាចូលចិត្តដេកនៅលើធ្នើរ ដូចនេះគួររៀបចំធ្នើរមានកម្ពស់ទាបៗផុតពីដី កម្ពស់អាចចាប់ពី ០,៥ម៉ែត្រឡើងទៅ។




## គ)-ការរៀបចំអាងទឹកសិប្បនិម្មិតសម្រាប់ទាកាប៉ា

ករណីកន្លែងចិញ្ចឹមទាកាប៉ាមិនមានត្រពាំង ឬស្រះទឹកនោះកសិករត្រូវតែរៀបចំអាងទឹកដោយពុះធុងជ័រជាពីរ ឬចានដែកដាក់ទឹកឱ្យទាកាប៉ាលេង និងសម្រាប់លាងសម្អាតខ្លួនជាប្រចាំថ្ងៃ។

*(គួរប្ដូរទឹកចេញ១ទៅ២ ដង/ថ្ងៃ ដោយមើលទៅលើភាពកង្វក់របស់ទឹក ដើម្បីទាកាប៉ាមានសុខភាពល្អ)*




ជីកមាត់អាងខាងលើក្នុងទំហំទទឹង និងបណ្ដោយចាប់ពី១ម៉ែត្រ និងផ្ទៃបាតស្រះធ្វើរាងជម្រាលមុំ ៤៥ដឺក្រេ ជម្រៅ០,២៥ ទៅ០,៣ម៉ែត្រ។

### ៣-២-ការជ្រើសរើសពូជទាកាប៉ា

កត្តាសំខាន់ៗនៃការជ្រើសរើសពូជទាកាប៉ា ៖




- មានមាឌធំ និងដងខ្លួនវែង
- ចលនារឹងប៉ឹងស្វាហាប់
- មានរោម ស្លាបល្អភ្លឺរលោង និងភ្នែកភ្លឺថ្លាល្អ
- ជើងមានទ្រង់ទ្រាយល្អ មិនមានស្នាមរបួស
- ពូកែស៊ីចំណី និងផឹកទឹក
- ផលិតស៊ុតបានច្រើន
- មិនមានជម្ងឺ ឬមិនធ្លាប់កើតជម្ងឺឆ្លង

ប្រភេទទាកាប៉ា (Cairine Moschata) ជាពូជទាដែលល្អជាងគេសម្រាប់ផលិតកម្មសាច់។ ទាកាប៉ាឈ្មោលអាចមានទម្ងន់ពី៤,៦ ទៅ៦,៨គីឡូក្រាម/ក្បាល និងទាញីអាចមានទម្ងន់ពី ២,៧ទៅ៣,៦គីឡូក្រាម/ក្បាល ហើយអាចផលិតស៊ុតមធ្យម ៦០ទៅ១២០គ្រាប់/ឆ្នាំ។ កូនទាកាប៉ាមានភាពរឹងមាំងាយស្រួលចិញ្ចឹម។ ទាកាប៉ាប្រភេទនេះចូលចិត្តស៊ីស្មៅ និងដើររកចំណីនៅតាមវាលក្បែរៗផ្ទះ។

### ៣-៣-ការបង្កាត់ពូជទាកាប៉ា



ត្រូវជ្រើសរើសទាកាប៉ាសម្រាប់ទុកធ្វើពូជនៅអាយុ ៦ទៅ ៧សប្ដាហ៍ ដែលមានទំហំធំជាងគេក្នុងសម្បុក ២ទៅ៣ក្បាល។ ទាអាចចាប់ផ្ដើមបង្កាត់ពូជពីអាយុ៧ ទៅ ៨ខែ។ មេទាកាប៉ាផ្ដល់ស៊ុតពីអាយុ៧ខែឡើងទៅ។



- ទាកាប៉ាមេ១ក្បាលអាចភ្ញាស់កូនបានពី ១២ ទៅ ១៥ ក្បាល/លើក
- ត្រូវដាក់បង្កាត់មេទាពី៥ ទៅ៦ក្បាល ជាមួយទាកាប៉ាឈ្មោល ១ក្បាល
- ប្ដូរបារៀងរាល់១ឆ្នាំម្ដងជៀសវាងការជាន់ឈាម
- កាត់រោមស្លាបរឹង(រំលងមួយៗ)របស់ទាកាប៉ាចេញ ដើម្បីកុំឱ្យហើរ ពិសេសទាដែលមានទម្ងន់ស្រាល ឬស្គមៗ។

### ៣-៤-ការភ្ញាស់ស៊ុតទាកាប៉ាតាមលក្ខណៈធម្មជាតិ

*-ការរៀបចំសម្បុកពងទាកាប៉ា*

មេទាកាប៉ាក្រាប និងភ្ញាស់ស៊ុតដោយខ្លួនឯង។ កសិករចិញ្ចឹមត្រូវរៀបចំសម្បុកឱ្យបានល្អត្រឹមត្រូវ និងមានភាពកក់ក្ដៅដោយ÷

-ត្រូវរៀបចំដោយប្រើចំបើង សម្បុកកេស ឬកម្ទេចឈើ ដាក់ក្រាលពីក្រោមដើម្បីកុំឱ្យកម្ដៅសាយភាយចេញ និងការពារខ្យល់ប៉ះផ្ទាល់ទៅនឹងស៊ុត ដែលនាំឱ្យស៊ុតបាត់បង់កម្ដៅដែលផ្ដល់ពីមេទា

-សម្បុកគួរធ្វើពីចំបើងស្ងួត ហើយមាត់សម្បុកត្រូវរុំចំបើងជារង្វង់ជុំវិញ

-ស៊ុតក្នុងសម្បុកមិនត្រូវដាក់នៅចំពីក្រោមកម្ដៅថ្ងៃ ឬសើមឡើយ

-សម្បុកត្រូវស្អាត (មិនប្រឡាក់) ស្ងួត កក់ក្ដៅ និងទំហំល្មមសម្រាប់ទាក្រាប

-ចរិកពីធម្មជាតិរបស់ទាកាប៉ាចូលចិត្តក្រាបពងនៅលើកម្រាលទ្រុងផ្ទាល់ដី កន្លែងមិនសូវមានពន្លឺ ស្ងប់ស្ងាត់ និងមានសុវត្ថិភាព

-មេទាផ្ដល់ស៊ុតនៅពេលព្រឹកព្រលឹម ឬពេលយប់

-ពេលកំពុងក្រាបភ្ញាស់ កសិករត្រូវដាក់ចំណី និងទឹកគ្រប់គ្រាន់នៅក្បែរមេទាកាប៉ា កុំឱ្យមេទាកាប៉ាចេញឆ្ងាយពីសម្បុកយូរពេកបណ្ដាលឱ្យស៊ុតត្រជាក់ និងញាស់មិនបានច្រើន

-កូនទាកាប៉ាចំណាយពេល២ទៅ៣ថ្ងៃសម្រាប់ចោះសំបក និងញាស់ ដូច្នេះមិនត្រូវប្រញាប់ប្រញាល់ជួយបកសំបកពេកនោះទេ។





### ៣-៥-ការថែទាំកូនទាកាប៉ា

-កូនទាកាប៉ាទើបញាស់ត្រូវការផ្ដល់កម្ដៅបន្ថែម ទឹក ចំណី និងមានខ្យល់អាកាសចេញចូលល្អ

-មិនត្រូវឱ្យកូនទាកាប៉ាតូចៗអាយុក្រោម៨ថ្ងៃ ចូលលេងទឹកក្នុងអាង

-កូនទាកាប៉ាអាយុលើសពី៨ថ្ងៃ អាចដាក់ឱ្យលេងទឹកយូរបំផុត ២ទៅ៣នាទីប៉ុណ្ណោះ តែកុំឱ្យលេងទឹករហូតដល់រងាររញ៉ីរញ៉ាក់

-កូនទាកាប៉ាមានអាយុក្រោម ២សប្ដាហ៍ត្រូវថែរក្សាឱ្យមានសុវត្ថិភាព និងរៀបចំសម្រាប់ដាក់កូន ទាកាប៉ាតូចៗឱ្យបានកក់ក្ដៅ។

-មិនត្រូវឱ្យកូនទាកាប៉ានៅក្រោមទឹកភ្លៀងទេ ព្រោះកូនទាកាប៉ាមានអាយុក្រោម ៣ទៅ៤សប្ដាហ៍ពុំអាចទប់ទល់នឹងអាកាសធាតុបាន។

-ត្រូវផ្ដល់កម្ដៅបន្ថែមដូចជា អំពូលភ្លើង ឬភ្ជួមធ្យូង នៅពេលអាកាសធាតុត្រជាក់ជាងធម្មតា

-កូនទាកាប៉ាអាយុចាប់ពី ៣ទៅ៤ខែឡើងអាចមានលទ្ធភាពទប់ទល់អាកាសធាតុអាក្រក់បាន

-ដាក់កូនទាកាប៉ាក្នុងទីធ្លាចិញ្ចឹម និងកន្លែងដេកស្របទៅតាមមាឌ អាយុ និងទំហំដងខ្លួន



*បរិមាណដង់ស៊ីតេទាកាប៉ាដាក់ចិញ្ចឹម*

បរិមាណអតិបរមានៃដង់ស៊ីតេទាកាប៉ាដាក់ចិញ្ចឹមក្នុងទ្រុង (ដេកយប់)មានទីធ្លាបិទជិតគឺ÷

| ***អាយុទាកាប៉ា (សប្ដាហ៍)*** | ***ដង់ស៊ីតេ (ក្បាល)/ម៉ែត្រការ៉េ*** |
|---|---|
| អាយុក្រោម ១សប្ដាហ៍ | ៥០ |
| អាយុចន្លោះពី ១ ទៅ៤សប្ដាហ៍ | ២០ |
| អាយុចន្លោះពី ៤ ទៅ៨សប្ដាហ៍ | ៨ |
| អាយុចាប់ពី ៨សប្ដាហ៍ឡើង | ៥ |
| មេបាពូជ | ៤ |

## ៣-៦-ទឹក និងចំណីទាកាប៉ា

តម្រូវការសារធាតុចិញ្ចឹមរបស់ទាកាប៉ាក៏មិនខុសគ្នាពីបក្សីផ្សេងៗផងដែរ ដើម្បីលូតលាស់ ធំធាត់ បន្តពូជ ទាត្រូវការសារធាតុចិញ្ចឹមសំខាន់ៗដូចជា÷ទឹក ប្រូតេអ៊ីន ថាមពល វីតាមីន និងសារធាតុរ៉ែ ដែលមាននៅក្នុង បន្លែបៃតង គ្រាប់ធញ្ញជាតិ សំបកក្តាមខ្យង ខ្ចៅ ដង្កូវ និងសត្វល្អិតផ្សេងៗ។ល។

***ក-តម្រូវការទឹក***



ទឹកមានសារៈសំខាន់ចូលរួមជួយដំណើរឈាមរត់ បង្កើនផលិតកម្មស៊ុត និងការលូតលាស់។ ទឹកធ្វើឱ្យចំណីទន់ និងជួយរំលាយអាហារ ការស្រូប និងការដឹកជញ្ជូនសារធាតុចិញ្ចឹមទៅគ្រប់សរីរាង្គ។ ទាពេញវ័យត្រូវការផឹកទឹកមិនតិចជាង២លីត្រ/ក្បាល ជារៀងរាល់ថ្ងៃ។

***ចំណាំ***÷ទាកាប៉ាផឹកទឹកមិនគ្រប់គ្រាន់អាចបណ្តាលឱ្យការរំលាយអាហារមិនបានល្អ ផលិតកម្មស៊ុតថយចុះយ៉ាងរហ័ស មិនមានភាពស្វាហាប់ រហ័សរហួន។

***ខ-ចំណីកូនទាកាប៉ា (អាយុពី ១ថ្ងៃ-២សប្តាហ៍)***

-ការផ្តល់ចំណីដល់កូនទាកាប៉ាតូចៗត្រូវធ្វើឡើងបន្ទាប់ពីកូនទាញាស់បាន ២៤ម៉ោង

-ត្រូវផ្តល់ចំណីក្រុមហ៊ុន (ចំណីកូនទា ឬកូនមាន់ដែលមានប្រូតេអ៊ីនពី ២០ ទៅ២២% និងត្រូវផ្តល់ទឹកស្អាតជានិច្ច

-កូនទាចូលចិត្តចំណីស្ងោរដូចជា អង្ករ កន្ទក់ បន្លែបៃតង ឬរុក្ខជាតិដុះក្នុងទឹក និងចំណីដែលមានប្រូតេអ៊ីនមួយចំនួនទៀតដូចជា កំណាត់ជន្លេន ខ្យងខ្ចៅ កូនត្រី ។ល។

***គ-ការផ្តល់ចំណីដល់កូនទាកាប៉ា (អាយុពី២-៤សប្តាហ៍)***

-អាចផ្តល់ចំណីកូនទាបន្ត ព្រោះប្រព័ន្ធរំលាយអាហារវាពុំទាន់មានភាពរឹងមាំពេញលេញនៅឡើយ

-ចំណីមានគ្រាប់ល្អិតៗ និងដាក់ទឹកផ្សើម ឬអាចលាយបន្ថែមរុក្ខជាតិបៃតង ឬស្លឹកបន្លែនានា។

-លាយចំណីកូនទាពាក់កណ្តាល និងចំណីរកបានក្នុងភូមិពាក់កណ្តាល។




*កូនទាកាប៉ាអាយុ២៥ថ្ងៃ ឈ្មោលតែងលូតលាស់ធំជាងញី កូនទាកាប៉ាលេខ(១និង២)ឈ្មោល ចំណែកលេខ(៣ និង៤)ញី*

*ឃ-ការផ្តល់ចំណីដល់ទាកាប៉ាសាច់ (អាយុលើសពី ៤សប្តាហ៍)*

ទាកាប៉ាជំទង់ និងពេញវ័យត្រូវការប្រូតេអ៊ីនប្រមាណ ១៦% ទៅ២០% មានច្រើនរបៀបក្នុងការផ្សំចំណីសម្រាប់ទាកាប៉ាសាច់ ÷

-*របៀបទី១*÷ ប្រើកន្ទក់ ១០០គីឡូក្រាម លាយជាមួយមេចំណីជ្រូកសាច់១០គីឡូក្រាម ករណីមានកូនត្រីល្អិត បន្លែ ឬកាកសំណល់ផ្ទះបាយអាចបន្ថែម ដើម្បីជួយកាត់បន្ថយថ្លៃដើមចំណី និងបង្កើនសារធាតុចិញ្ចឹមជួយឱ្យទាកាប៉ាឆាប់ធំធាត់ផងដែរ។

-*របៀបទី២*÷ផ្សំពីសមាសធាតុរួមផ្សំច្រើនប្រភេទ ដែលងាយស្រួលស្វែងរកក្នុងភូមិដូចជា ចុងអង្ករ កន្ទក់ ពោត កាកស្រាបៀរ កូនដង្កូវ ជន្លេន ខ្យងខ្មៅ ក្បាលត្រីឬត្រីនុយ បន្លែបៃតង ឬរុក្ខជាតិដុះក្នុងទឹក ។ល។ ក្នុងដំណាក់កាលនេះគួរលាយចំណីបាវក្រុមហ៊ុន ១/៣ និងចំណីរកបានក្នុងភូមិ ២/៣។

***ង-ចំណីមេបាពូជ***

អាហារទាកាប៉ាចូលចិត្តស៊ីជាចម្បងគឺ គ្រាប់ធញ្ញជាតិ បន្លែបៃតង ស្មៅ កាកសំណល់បន្លែពីផ្ទះបាយ មើម កូន ពន្លករុក្ខជាតិដែលដុះនៅលើគោក ឬក្នុងទឹក និងប្រភេទអាហារដែលមានជាតិសាច់មួយចំនួនដូចជា កូនត្រី កូនកង្កែប ខ្យង ដង្កូវ រុយ មូស ជន្លេន និងសត្វល្អិតៗនានា។

ទាកាប៉ាត្រូវការចំណីដែលមានគ្រឿងផ្សំសំខាន់ៗ ÷

-ចំណីថាមពល (ជាតិម្សៅ ប្រេង ខ្លាញ់ )ដូចជា÷ មើមដំឡូងមី ពោត ចុងអង្ករ ត្រាវ ដំឡូង កន្ទក់ ស្រូវ ស្កររង្វរ។ល។

-ប្រូតេអ៊ីន (ជាតិសាច់)ដូចជា÷ ស្មៅខ្ចី បន្លែ ដំណាំចំណីសត្វ រុក្ខជាតិតូចៗដុះក្នុងទឹក កូនត្រី ខ្យងខ្មៅ ក្តាម កំពិស ម្សៅត្រី ជន្លេន... ។ល។

-វីតាមីន សារធាតុរ៉ែ និងទឹក។

**រូបមន្តផ្សំចំណីទាកាប៉ា ÷** សម្រាប់ដំណាក់កាលលូតលាស់ខុសៗគ្នាក្នុងបរិមាណ១០០ គ.ក្រ

| សមាសភាពធាតុផ្សំចំណី | អាយុពី១ថ្ងៃ ដល់៦សប្តាហ៍ | មានអាយុលើស ៦សប្តាហ៍ | ត្រៀមលក់ ឬ ទាកាប៉ាពង |
|---|---|---|---|
| ពោតក្រហម | ៤៥ | ៤០ | ៤០ |
| កន្ទក់ | ២៥ | ៣៣ | ៣៣ |
| កាកដូង | ៣ | ១០ | ៥ |
| ម្សៅស្លឹកកន្ធិថេត | ៣ | ៨ | ៥ |
| ម្សៅបង្គារ | ២៣ | ៨ | ១៦ |
| អំបិល | ០.៥ | ០.៥ | ០.៥ |

| | | | |
|---|---|---|---|
| ប្រេមិច (វីតាមីន និងសារធាតុរ៉ែ) | ០.៥ | ០.៥ | ០.៥ |
| សរុប | ១០០ | ១០០ | ១០០ |

ក្រៅពីនោះ អាចធ្វើការរៀបចំបង្កើតសមាធាតុផ្សំចំណីបន្ថែមសម្រាប់ទាកាប៉ាដូចជា÷

-បង្កើតសួនបន្លែ ត្រកួន ផ្ទី និងស្មៅ

-ដាំប្រភេទបន្លែទ្រើងពីលើទីធ្លាទាកាប៉ាដើរលេង (ននោងជ្រុង ននោងមូល ឃ្លោក ម្រះ។ល។)

-ដាំចកអាសូឡា ឬចកបាយទាក្នុងស្រះ ឬអាងស៊ីម៉ងដ៍

-ចិញ្ចឹមជន្លេនក្រហម

## ៤-វិធី ការការពារ និងការថែរក្សាសុខភាពទាកាប៉ា

### ជំងឺតែងជួបប្រទះលើទាកាប៉ា

***ក-ជំងឺអាសន្នរោគ÷*** កើតឡើងលើទាកាប៉ាគ្រប់វ័យ

***រោគសញ្ញា÷***

-ដំណើរល្ងើយៗ និងខ្សោយកម្លាំង

-មិនសូវស៊ីចំណី ស្រេកទឹកខ្លាំង

-ទាកាប៉ាគ្រវីក្បាលញឹកញាប់ និងរាគពណ៌លឿងខ្ចីលាយជាមួយទឹក

-ភ្នែកសើម និងច្រមុះមានស្លេស

-អត្រាបាត់បង់ចន្លោះពី ៥%ទៅ៣៥% ឆ្លងរហ័សតាមរយៈស្លេស និងការប៉ះពាល់ផ្ទាល់រវាងទាឈឺ និងទាជារស់នៅក្នុងហ្វូងតែមួយ

***វិធីសាស្ត្រការពារនិងព្យាបាល ÷***

-ចាក់វ៉ាក់សាំងការពារជម្ងឺអាសន្នរោគ (ចាក់សាច់ដុំទ្រូង) លើកូនទាកាប៉ាអាយុបាន២ ទៅ៣សប្តាហ៍

-វ៉ាក់សាំងអាសន្នរោគលើកទី២ ចាក់ក្រោយលើកទី១ រយៈពេល២១ថ្ងៃក្រោយ និងរំលឹកវ៉ាក់សាំងអាសន្នរោគ រៀងរាល់៥ខែម្តង(សម្រាប់ទាកាប៉ាទុកពូជ)

-ការប្រើប្រាស់ថ្នាំសម្រាប់ព្យាបាលពុំសូវមានប្រសិទ្ធភាពទេ ដោយសារមេរោគរីករាលដាលយ៉ាងឆាប់រហ័ស

***ខ-ជំងឺប៉េស្តទាកាប៉ា ÷***

ជំងឺនេះមានរោគសញ្ញាស្រដៀងនឹងរោគសញ្ញាជំងឺអាសន្នរោគដែរ តែមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនដូចជាហ្វូងទាងាប់យ៉ាងឆាប់រហ័សក្នុងចំនួនច្រើន។

***រោគសញ្ញា÷***

-ខ្សោយកម្លាំង និងដំណើរខ្ទើចៗដោយគ្មានការហើម ឬឡើងកម្តៅត្រង់សន្លាក់

-មានហូរទឹកភ្នែក និងរោមជុំវិញភ្នែកមានជាប់ពពុះទឹក

-ក្បាលឱនចុះក្រោម និងធ្លាក់ស្លាប មិនអាចហើរបាន

***វិធីសាស្ត្រការពារនិងព្យាបាល÷***

-ចាក់វ៉ាក់សាំងការពារជម្ងឺប៉េស្តទាកាប៉ា (ចាក់សាច់ដុំភ្លៅ) ÷

-ចាក់លើកូនទាកាប៉ាអាយុ ៤សប្តាហ៍ និងរំលឹករៀងរាល់៥ខែម្តង

-***<u>ចំណាំ</u>***÷ជំងឺប៉េស្តទាកាប៉ាជាប្រភេទវីរុសពុំមានថ្នាំព្យាបាលទេ

***<u>គ-ជំងឺបង្កឡើងដោយពួកបរាសិត</u>***

-បរាសិតដែលតែងកើតលើទាកាប៉ាចែកចេញជា២ប្រភេទគឺ÷ ***បរាសិតខាងក្រៅនិងបរាសិតខាងក្នុង***

- ***<u>បរាសិតខាងក្នុងមានដូចជា</u>***÷ Flukes Tapeworms Roundworms Coccidia Hairworms Gizzard worms និង Intestinal worms

- ***<u>បរាសិតខាងក្រៅមានដូចជា</u>***÷ Duck lice និង Gapeworms

***ដើម្បីទប់ទល់បញ្ហាបរាសិតខាងក្នុងនិងខាងក្រៅ កសិករអាចអនុវត្តន៍វិធានការដូចខាងក្រោម÷***

-សម្អាត និងធ្វើអនាម័យកន្លែងរស់នៅរបស់ទាកាប៉ាជាប្រចាំ

-ប្រើប្រាស់ថ្នាំសម្លាប់មេរោគ និងថ្នាំសម្លាប់សត្វល្អិត

-ថែរក្សាសត្វឱ្យមានសុខភាពល្អតាមរយៈការផ្តល់ចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់

-ជៀសវាងឱ្យបក្សីព្រៃចូលមកទីធ្លាចិញ្ចឹមទាកាប៉ា

-អាចប្រើប្រាស់ថ្នាំទម្លាក់បរាសិតដោយលាយច្របល់ជាមួយចំណីមានដូចជា ÷ Fenbendazole, Albendazole, Ivermectin...

-ផ្តល់ជាលើកដំបូងលើកូនទាកាប៉ាអាយុបាន ២ខែ ដោយយកថ្នាំលាយច្របល់ជាមួយចំណីទា។

## ៥-តម្លៃ និងទីផ្សារ

**៥-១-តម្លៃ÷** ជាធម្មតាឈ្មួញប្រមូលទិញក្នុងតម្លៃបោះដុំថេរពេញមួយឆ្នាំគឺ ១០,០០០រៀល/គ.ក្រ និងលក់រាយក្នុងស្រុកតម្លៃ ១២,០០០រៀល/គ.ក្រ។

**៥-២-ទីផ្សារ÷** កសិករអាចលក់ទាកាប៉ាសាច់រស់ចេញទៅឈ្មួញកណ្តាលដែលមកយកដល់កសិដ្ឋានទៅលក់បន្តនៅភ្នំពេញ និងចែកចេញតាមទីប្រជុំជន និងទីផ្សារ។

### ៥-៣-គម្រោងនៃការចំណាយលើការចិញ្ចឹមទាកាប៉ាសាច់ ១,០០០ក្បាល/វគ្គ

គម្រោងចិញ្ចឹមទាកាប៉ាសាច់នេះត្រូវបានក្រុមការងារបច្ចេកទេសនៃធនាគារ អេ.អ.ឌី.ប៊ី ចុះសិក្សានៅកសិដ្ឋានចិញ្ចឹមទាកាប៉ា នៅភូមិត្រពាំងចាន់ ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។

-ទំហំផ្ទៃកសិដ្ឋានសរុប ÷ ០,៥ហិកតា

-ចំនួនវគ្គ/ឆ្នាំ ÷ ៣វគ្គ/ឆ្នាំ *(១វគ្គប្រើពេល៣ខែ និងទុកទ្រុងឱ្យទំនេរកន្លះខែទៅ១ខែ ដើម្បីសម្អាត)*

-ទំហំទ្រុង ÷ ទទឹង១០ម៉ែត្រ និងបណ្តោយ៣០ម៉ែត្រ

ទុនចំណាយពេលចាប់ផ្តើម÷ **៣៣,០៨០,០០០រៀល** ក្នុងនោះរួមមាន÷

| **ចំណាយវិនិយោគលើការរៀបចំទ្រុង របង និង ឧបករណ៍សម្ភារៈផ្សេងៗ (រៀល)** | **ចំណាយលើការចិញ្ចឹម-ថែទាំ (ចំណី និងថ្នាំ) (រៀល)** | **ចំណាយសរុប (រៀល)** |
|---|---|---|
| **12,480,000** | **20,600,000** | **33,080,000** |

### ៥-៤-ការប្រមូលផលទាកាប៉ា÷

ដោយផ្អែកលើនិន្នាការតម្លៃ និងអត្រាស្លាប់កូនទាកាប៉ាអាយុក្រោមអាយុ១៤ថ្ងៃ

-ទាកាប៉ាសាច់ចំណាយរយៈពេលចិញ្ចឹមជាង៣ខែ។ ទាញីអាចមានទម្ងន់ពី២ទៅ២,៨គ.ក្រ/ក្បាល រីឯទាឈ្មោលអាចមានទម្ងន់ពី៣ទៅ៤គ.ក្រ/ក្បាល (ជាមធ្យមទម្ងន់ទាកាប៉ាសាច់ ៣គ.ក្រ/ក្បាល) ។

-អត្រាបាត់បង់មធ្យមអាចមានចន្លោះពី ៤%ទៅដល់១០% គឺអាស្រ័យលើការថែទាំ ចំណី ទឹក និងពូជ

-អត្រាបាត់បង់អាចមានរហូតដល់៥០% ករណីផ្ទុះជំងឺនៅពេលកូនទាអាយុក្រោម១៤ថ្ងៃ ។

-*តាមរយៈការសិក្សា* កសិដ្ឋានចិញ្ចឹមទាកាប៉ាមានអត្រាបាត់បង់ ៦%

-***សម្គាល់÷*** ការចិញ្ចឹមទាកាប៉ាសាច់ក្នុង១វគ្គមានរយៈពេលជាង៣ខែជាង ដោយទុកចន្លោះរយៈពេល១ខែ ដើម្បីសម្អាតទ្រុង និងប្រើថ្នាំសម្លាប់មេរោគ មុនដាក់កូនទាកាប៉ាថ្មីចូល ដូច្នេះអាចចិញ្ចឹមបានចំនួន៣វគ្គ/ឆ្នាំ។

**៦-ការវិភាគសេដ្ឋកិច្ច÷** លើការចិញ្ចឹមទាកាប៉ាសាច់ចំនួន ១,០០០ក្បាល/វគ្គ÷

-ទម្ងន់ជាមធ្យម ៣គ.ក្រ/ក្បាល

-តម្លៃជាមធ្យម ១០,០០០រៀល/គ.ក្រ

| ការវិភាគសេដ្ឋកិច្ចលើការចិញ្ចឹមទាកាប៉ាសាច់<br>របស់កសិករនៅ ឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង | | | | | | |
|---|---|---|---|---|---|---|
| **បរិយាយ** | **ឯកត្តា** | **ចំនួនឯកត្តា** | **តម្លៃ១ឯកត្តា** | **ទឹកប្រាក់សរុប (រៀល)** | **ចំនួនសាររំលស់** | **ទឹកប្រាក់សរុប (រៀល)** |
| **១-ចំណូលសរុប/វគ្គ** | | | | | | **28,200,000** |
| ចំណូលពីការលក់ទាកាប៉ា | ក្បាល | 940 | 30,000 | 28,200,000 | | 28,200,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **20,927,417** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **20,600,000** |
| កូនទាកាប៉ា | ក្បាល | 1,000 | 4,000 | | | 4,000,000 |
| កន្ទក់ | គ.ក្រ | 10,000 | 1,100 | | | 11,000,000 |
| ចំណីកូនមាន់ | គ.ក្រ | 30 | 2,333 | | | 70,000 |
| ចំណីកូនទា | គ.ក្រ | 300 | 2,000 | | | 600,000 |
| មេចំណីជ្រូកសាច់ | គ.ក្រ | 990 | 3,500 | | | 3,465,000 |
| ថ្លៃអគ្គិសនី | គី.វ៉ាត់ | 100 | 730 | | | 73,000 |
| ថ្នាំនិងវីតាមីន | គ.ក្រ | 2 | 24,000 | | | 48,000 |
| វ៉ាក់សាំងប៉េស្ត | ដប | 1 | 20,000 | | | 20,000 |
| វ៉ាក់សាំងអាសន្នរោគ | ដប | 1 | 80,000 | | | 80,000 |
| កម្លាំងពលកម្ម | ខែ | 3 | 400,000 | | | 1,200,000 |
| ថ្នាំទម្លាក់សត្វល្អិត | កញ្ចប់ | 1 | 20,000 | | | 20,000 |
| ថ្នាំសម្លាប់មេរោគ | ដប | 1 | 24,000 | | | 24,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ** | | | | **12,480,000** | | **327,417** |
| រោងទាកាប៉ា (ទទឹង១០ម៉ែត្រ បណ្តោយ៣០ម៉ែត្រ) | រោង | 12,000,000 | 1 | 12,000,000 | 45 | 266,667 |
| សំណាញ់ព័ទ្ធជុំវិញបរិមាណទ្រុងមេបា | គ.ក្រ | 10 | 25,000 | 250,000 | 30 | 8,333 |

| | | | | | | |
|---|---|---|---|---|---|---|
| កម្រាល (ចំបើង ឬអង្កាម) | ដុំ | 1 | 5,000 | 5,000 | 1 | 5,000 |
| ស្នូកទឹក | ចំនួន | 2 | 80,000 | 160,000 | 30 | 5,333 |
| ស្នូកចំណី | ចំនួន | 10 | 2,500 | 25,000 | 12 | 2,083 |
| អំពូលកម្តៅ | ចំនួន | 10 | 4,000 | 40,000 | 1 | 40,000 |
| **៣-ចំណេញសរុប** | | | | | | **7,272,583** |
| **ថ្លៃដើមចំណាយលើទាកាប៉ាសាច់មួយក្បាល** | | | | | | **22,263** |
| **ចំណេញលើទាកាប៉ាមួយក្បាល** | | | | | | **7,737** |

*ប្រភព*÷ចុះសាកសួរកសិករចិញ្ចឹមទាកាប៉ាផ្ទាល់នៅឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

### ៦-១-ការវិភាគលើតម្លៃលក់ទាកាប៉ាសាច់អាយុ៣ខែ

| *ចំនួនទាកាប៉ា* | *ទម្ងន់/ក្បាល* | *ទម្ងន់សរុប* | *តម្លៃ/គ.ក្រ* | *ចំណូលសរុប* | *ចំណាយសរុប* | *ចំណេញសរុប* |
|---|---|---|---|---|---|---|
| 940 | 3 | 2,820 | 9,000 | 25,380,000 | 20,927,417 | **4,452,583** |
| 940 | 3 | 2,820 | 10,000 | 28,200,000 | 20,927,417 | **7,272,583** |
| 940 | 3 | 2,820 | 11,000 | 31,020,000 | 20,927,417 | **10,092,583** |
| 940 | 3 | 2,820 | 12,000 | 33,840,000 | 20,927,417 | **12,912,583** |

### ៦-២-ការវិភាគទៅលើអត្រាបាត់បង់( ៤%, ៦%, ១២%, ២៥%, ៥០%)

| អត្រាបាត់បង់ (%) | ចំនួន (ក្បាល) | ទម្ងន់មធ្យម /ក្បាល (គ.ក្រ) | ទម្ងន់សរុប (គ.ក្រ) | តម្លៃ/គ.ក្រ (រៀល) | ចំណូលសរុប (រៀល) | ចំណាយ សរុប(រៀល) | ចំណេញ សរុប (រៀល) |
|---|---|---|---|---|---|---|---|
| 4 | 960 | 3 | 2,880 | 10,000 | 28,800,000 | 21,249,438 | **7,550,562** |
| 6 | 940 | 3 | 2,820 | 10,000 | 28,200,000 | 20,927,417 | **7,272,583** |
| 12 | 880 | 3 | 2,640 | 10,000 | 26,400,000 | 19,961,353 | **6,438,647** |
| 25 | 750 | 3 | 2,250 | 10,000 | 22,500,000 | 17,868,215 | **4,631,785** |
| 50 | 500 | 3 | 1,500 | 10,000 | 15,000,000 | 13,842,949 | **1,157,051** |

*កំណត់សម្គាល់÷ការចំណាយសរុបប្រែប្រួលដោយបរិមាណចំណីថយចុះទៅតាមអត្រាបាត់បង់កូនទានៅអាយុក្រោម២សប្តាហ៍*

## ៧-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះសិក្សាឃើញថាកសិដ្ឋានអាចជួបនូវហានិភ័យមួយចំនួនជាយថាហេតុលើដំណើរការចិញ្ចឹមទាកាប៉ាដែលនាំឱ្យបង្កផលវិបាក និងប៉ះពាល់ដល់សមត្ថភាពផលិតកម្ម ដូចនេះកសិករគួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងលើហានីភ័យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។ ហានិភ័យទាំងនោះមាន÷

| ល.រ | ប្រភេទ ហានិភ័យ | ការពិពណ៌នា ពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យ ផលិតកម្ម | កូនទាកាប៉ាដែលមានជំងឺតពូជពីមេបា និងកូនទាកាប៉ាដែលមានសុខភាពខ្សោយ ដឹកជញ្ជូនយូរពេក | -សិក្សាប្រវត្តិពីកសិដ្ឋានលក់ពូជឱ្យបានច្បាស់លាស់អំពីមេបាពូជ<br>-ត្រូវរើសកូនទាកាប៉ាដែលមានសុខភាពល្អមានទំហំប៉ុនៗគ្នា មានរោមភ្លឺរលោង មិនស្វិតជើង<br>-សន្ទាក់ជើងល្អ ដំណើររហ័យរហួន សំឡេងលឺច្បាស់<br>-មានកែវភ្នែកភ្លឺថ្លា<br>-តាមដានទម្ងន់មេបា និងប្រវត្តិដើមនៃការបង្កាត់ពូជ។ |
| | | កង្វះខាតទីធ្លាដាំស្មៅ ពុំមានស្រះទឹកសម្រាប់ទាហែល លេង និងខ្វះទឹកស្អាតសម្រាប់ផឹក | -រៀបចំដាំស្មៅឱ្យបានច្រើនប្រភេទពិសេសស្មៅកម្ពស់ទាបជាងកន្លះម៉ែត្រ មានស្លឹកទន់ ប្រូតេអ៊ីនខ្ពស់ លើផ្ទៃដីដែលមានទំហំសមាមាត្រនឹងចំនួនទាកាប៉ា<br>-មានរៀបចំស្រះទឹកសម្រាប់ទាកាប៉ាហែលលែង<br>-មានទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ប្រចាំ<br>-រៀបចំកម្រាលទ្រុងស្ងួតល្អ ពិសេសពេលកូនទាកាប៉ានៅតូច |
| ២ | ហានិភ័យទីផ្សារ | តម្លៃទីផ្សារទាកាប៉ាប្រែប្រួលមិនច្បាស់លាស់ដោយមានការប្រកួតប្រជែង ជាពិសេសពីប្រទេសជិតខាង | -ស្វែងរកទីផ្សារ ឬឈ្មួញប្រមូលទិញឱ្យបានច្រើនកន្លែង<br>-ស្វែងរកហាង ភោជនីយដ្ឋានដែលមានតម្រូវការជាប្រចាំ និងលទ្ធភាពផ្គត់ផ្គង់ច្បាស់លាស់<br>-រកទីផ្សារលក់រាយក្នុងតំបន់ទៅអ្នកបរិភោគផ្ទាល់ |
| ៣ | ហានិភ័យ ហិរញ្ញវត្ថុ | ខ្វះថវិកានៅក្នុងដំណើរការចិញ្ចឹម | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ |

| | | | |
|---|---|---|---|
| | | ពេលខ្លះត្រូវបង្ខំចិត្តលក់ក្នុងរដូវកាលដែលទាមានតម្លៃទាប | -ត្រូវរកទុនឥណទានដែលមានអត្រាការប្រាក់ទាបសមរម្យ<br>-កំណត់បរិមាណទាដែលត្រូវចិញ្ចឹមទៅតាមទំហំទុន<br>-ដាក់ទាកាប៉ាចិញ្ចឹមក្នុងទ្រុងនូវបរិមាណសមស្រប ដោយដាក់ចិញ្ចឹមវិលជុំជា៣ទ្រុង ១ខែដាក់មួយទ្រុងដើម្បីមានទុនបង្វិលលឿន |
| ៤ | **ហានិភ័យបរិស្ថាន** | មានក្លិនស្អុយសាយភាយទៅអ្នករស់នៅជិតខាង | -ត្រូវចិញ្ចឹមនៅក្នុងចម្ការ ឬឆ្ងាយផ្ទះប្រជាជនរស់នៅ<br>-ត្រូវធ្វើអនាម័យជាប្រចាំ និងរៀបចំប្រព័ន្ធជីវសុវត្ថិភាព |

## ៨-សេចក្តីសន្និដ្ឋាន

ទាកាប៉ាជាបក្សីធំធាត់លឿន ធន់ខ្លាំងទៅនឹងអាកាសធាតុត្រជាក់ ងាយស្រួលចិញ្ចឹម និងផ្តល់ចំណីព្រមទាំងមានទីផ្សារល្អទាំងបោះដុំនិងលក់រាយ។ តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមទាកាប៉ារបស់កសិករនៅខេត្តកំពង់ឆ្នាំង លើការចិញ្ចឹមទាកាប៉ាសាច់ ១,០០០ក្បាល ដោយប្រើពេល៣ខែ/វគ្គ ទទួលបានទម្ងន់ជាមធ្យម ៣គ.ក្រ/ក្បាល ស្មើនឹង ៣០,០០០រៀល/ក្បាល ដោយចំណាយថ្លៃដើមផលិត២២,៣០០រៀល/ក្បាល ទទួលបានប្រាក់ចំណេញប្រមាណ ៧,៧០០រៀល/ក្បាល។ ក្នុង ១វគ្គកសិករអាចទទួលបានប្រាក់ចំណេញជាង ៧លានរៀល ប៉ុន្តែប្រាក់ចំណេញអាចលើសឬតិចជាងនេះអាស្រ័យលើអត្រាបាត់បង់ និងការកាត់បន្ថយចំណាយលើចំណីតាមរយៈការប្រើប្រាស់កាកសំណល់ផ្ទះបាយ និងការប្រមូលបន្លែចាស់ៗតាមផ្សារមកកែច្នៃជាចំណីបន្ថែម។ ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា ការជ្រើសរើសពូជ ការថែទាំដោយធ្វើអនាម័យស្នូកទឹក ចំណី និងអាងទឹកសម្រាប់ទាចុះសម្អាតខ្លួន ប្រភពចំណីក្នុងតំបន់ដែលអាចរកបានក្នុងតម្លៃទាប ធ្វើកម្មវិធីវ៉ាក់សាំងបានទៀងទាត់ និងមានទីផ្សារបោះដុំច្បាស់លាស់។

## ប្រភពនៃការសិក្សាស្រាវជ្រាវ

១/កសិករចិញ្ចឹមទាកាប៉ានៅឃុំត្រពាំងចាន់ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

២/ឯកសារការចិញ្ចឹមទាកាប៉ាជាលក្ខណ:គ្រួសារ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)

៣/Muscovy Duck Male Vs Female: Physical Differences & Sexing (earthlife.net)

៤/Pekin Duck vs Muscovy Duck - What is the Difference? - LearnPoultry

៥/Common Parasites in Ducks - The Happy Chicken Coop